# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាគោរពព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត
# ចំការទៀង ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩
# សូមចិញ្ចឹមគេខ្លួនឯងទៅ

**អត្ថបទទី១៖ កំណើតពិភពលោក ១៤,១៨-២០**

ស្តេចបានឲ្យពរលោកអប្រាមថា៖ សូមព្រះដ៏ខ្ពង់ខ្ពស់បំផុត ដែលបានបង្កើតផ្ទៃមេឃ និងផែនដី ប្រទានពរដល់លោកអប្រាម។ កណ ១៤,១៩

**អត្ថបទទី២៖ កូរិនថូសទី១ ១១,២៣-២៦**

រៀងរាល់ពេលដែលបងប្អូនពិសានំប៉័ង និងពិសាស្រាពីពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទិវង្គត រហូតដល់ព្រះអង្គយាងមកវិញ។ ១ករ ១១,២៦

**ដំណឹងល្អ៖ លូកា ៩,១១ខ-១៧**

ព្រះយេស៊ូយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ទ្រង់ងើបព្រះភ័ក្ត្រឡើងលើសរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានឲ្យសាវ័ក ដើម្បីឲ្យគេចែកបណ្តាជនបរិភោគ។ លក ៩,១៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាថ្ងៃឱឡារិកយើងគោរពព្រះយេស៊ូដែលជាព្រះលោហិតនិងជាព្រះកាយ ដើម្បីចិញ្ចឹមជីវិតយើងប្រចាំថ្ងៃយើងត្រូវការមានម្ហូបអាហារដើម្បីចិញ្ចឹមរាងកាយ ចំណេះដឹងដើម្បីចិញ្ចឹមខួរក្បាល ជំនឿដើម្បីចិញ្ចឹមផ្លូវវិញ្ញាណ។ ថ្ងៃនេះ ព្រះយេស៊ូបានប្រមូលមនុស្សយ៉ាងច្រើនដើម្បីព្យាបាល ដើម្បីអប់រំ ណែនាំឲ្យគេមានកម្លាំងកាយកម្លាំងចិត្ត។ ព្រះអង្គក៏បានឃើញគេឃ្លាន ពេលនោះព្រះយេស៊ូនឹកឃើញភ្លាមថា ដំបូងយើងត្រូវចិញ្ចឹមក្រពះកុំឲ្យគេមានអារម្មណ៍ថាឃ្លានឲ្យគេយល់ថាអ្វីដែលព្រះយេស៊ូបានអប់រំ អ្វីដែលព្រះអង្គបានធ្វើយ៉ាងសកម្មគឺណែនាំឲ្យគេពោរពេញដោយសេចក្តីសុខសាន្ត។ ព្រះយេស៊ូបានចិញ្ចឹមមនុស្សយ៉ាងច្រើនដោយបរិបូរណ៍ ព្រះអង្គបានបំភ្លឺគេអំពីការអស្ចារ្យ ដែលព្រះអង្គបានធ្វើក្នុងរយៈពេលប៉ុន្មានថ្ងៃដែលនៅជាមួយគេ ព្រះអង្គបានអប់រំគេ បានព្យាបាលអ្នកជំងឺ បានណែនាំឲ្យគេមានសេចក្តីសង្ឃឹម។ ម្ហូបអាហារដើម្បីចិញ្ចឹមជីវិតយ៉ាងពិសេសបំផុត គឺម្ហូបអាហារដែលមកពីស្ថានបរមសុខ ទឹកដែលសំខាន់បំផុតដើម្បីណែនាំឲ្យមានកម្លាំងកាយកម្លាំងចិត្ត គឺទឹកដែលមកពីស្ថានបរមសុខ។

ព្រះយេស៊ូមានបន្ទូលថា "**បើបងប្អូនសុខចិត្តដើរតាមខ្ញុំ សូមរៀបចំខ្លួនដោយលះបង់ចោលដោយអធិដ្ឋាន ដោយយកចិត្តទុកដាក់ធ្វើទានដល់បងប្អូនឯទៀតៗ**"។ ព្រះសហគមន៍សព្វថ្ងៃមានតួនាទីបីយ៉ាងគឺ៖

**ទីមួយ** ព្រះសហគមន៍បានរៀបចំពិធីបុណ្យ ណែនាំឲ្យព្រះសហគមន៍ចេះអធិដ្ឋានដោយថ្វាយបង្គំ អធិដ្ឋានស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ អភិបូជាជាពេលវេលាពិសេសដើម្បីប្រកាសដំណឹងល្អ។ យកចិត្តទុកដាក់រៀបចំអភិបូជា ដើម្បីណែនាំឲ្យយើងចូលនៅក្នុងការកោតសរសើរព្រះជាម្ចាស់ ដោយសារអភិបូជាជាកំពូលនៃជីវិត ជាពេលវេលាដែលយើងជួបព្រះជាម្ចាស់ផ្ទាល់ ជាពេលវេលាដែលព្រះកាយនិងព្រះបន្ទូលរបស់ព្រះគ្រីស្ដ យាងមកដើម្បីចិញ្ចឹមជីវិតរបស់យើង។

**ទីពីរ** ព្រះសហគមន៍បានរៀបចំការអប់រំជំនឿ បងប្អូនទាំងអស់ទទួលការអប់រំជំនឿហើយនៅបន្តទទួលទៀតពីគ្រូអប់រំជំនឿ។ គ្រូអប់រំជំនឿមុនគេ គឺលោកបូជាចារ្យនិងលោកអភិបាល ដើម្បីណែនាំឲ្យការអប់រំជំនឿចិញ្ចឹមចំណេះដឹង ដើម្បីយល់ពីព្រះសហគមន៍របស់យើង។

**ទីបី** ព្រះសហគមន៍បានរៀបចំកម្មវិធីសង្គហៈ មេត្តាករុណាដើម្បីចែករំលែកម្ហូបអាហារ សេចក្ដីសង្ឃឹម ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលថា "**សូមចិញ្ចឹមគេខ្លួនឯងទៅ**"។ នេះជាតួនាទីរបស់យើងជាព្រះសហគមន៍ ណែនាំឲ្យយើងមានសេចក្ដីសង្ឃឹម ណែនាំឲ្យមនុស្សដែលសង្គមមិនអើពើអាចចូលនៅក្នុងសង្គមយ៉ាងសកម្ម។ នៅតាមកន្លែងនីមួយៗ យើងធ្វើដូចម្ដេចដើម្បីឲ្យមេត្តាករុណារបស់យើងបង្កើតទំនាក់ទំនងយ៉ាងពិតៗ ដើម្បីណែនាំឲ្យជីវិតរបស់ព្រះជាម្ចាស់ធ្វើឲ្យបងប្អូនឯទៀតៗយល់ថាជីវិតគេមានតម្លៃ គេមានកម្លាំងដើម្បីទៅមុខទៀត។

ប្រទេសកម្ពុជាយើង មានអ្នកក្រីក្រ អ្នកអស់សង្ឃឹម បងប្អូនមួយចំនួនធំពោរពេញដោយទុក្ខលំបាក។ ដូច្នេះ តួនាទីរបស់យើងមិនមែនសង្គ្រោះប្រទេសកម្ពុជាទាំងមូល មិនមែនសង្គ្រោះណាមួយទាំងមូល ប៉ុន្ដែឲ្យយើងធ្វើខ្លះៗដើម្បីជាសញ្ញាសម្គាល់នៃជីវិតដែលយើងបានទទួលពីព្រះជាម្ចាស់។ កុំឲ្យយើងទទួលតែព្រះកាយ ទទួលតែការអប់រំ គឺឲ្យយើងអនុវត្តយ៉ាងជាក់ស្ដែងដូចព្រះយេស៊ូផ្ទាល់ ដែលណែនាំឲ្យព្រះសហគមន៍របស់យើងទៅជាសញ្ញាសម្គាល់នៃជីវិតដ៏បរិបូរណ៍ដែលព្រះយេស៊ូយាងមកដើម្បីឲ្យយើងទទួលរៀងៗខ្លួន។

យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គបន្ដធ្វើដំណើរជាមួយយើង ឲ្យយើងយកចិត្តទុកដាក់ខិតខំដើម្បីទៅមុខ ដើម្បីរីកចម្រើននៅក្នុងសេចក្ដីសុខសាន្ដ ដោយដឹងថាជីវិតរបស់យើងពោរពេញដោយសេចក្ដីសង្ឃឹម។ ឲ្យយើងយកចិត្តទុកដាក់ចាប់ពីពេលនេះតទៅ ដើម្បីឲ្យជីវិតរបស់យើងរកឃើញសេចក្ដីសុខនិងរកឃើញអំណរសប្បាយ ឲ្យយើងចេះមើលអ្វីដែលព្រះជាម្ចាស់បានរៀបចំសម្រាប់យើង។ អាម៉ែន៕